ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# សេចក្តីជូនព័ត៌មាន

## ស្តីពីលទ្ធផលនៃកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន

## នៅសាធារណរដ្ឋសិង្ហបុរី ពីថ្ងៃទី ០៤-០៦ ខែកុម្ភៈ ឆ្នាំ២០១៨

តបតាមការអញ្ជើញរបស់ឯកឧត្តមបណ្ឌិត វីវៀន បាឡាគ្រីស្ណស្នាន រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋសិង្ហបុរី ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំគណៈប្រតិភូកម្ពុជាចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន នៅថ្ងៃទី ថ្ងៃទី ០៤ ដល់ ០៦ ខែកុម្ភៈ ឆ្នាំ២០១៨ នៅសាធារណរដ្ឋសិង្ហបុរី។

កិច្ចប្រជុំចង្អៀតនេះបានពិភាក្សាប្រធានបទពាក់ព័ន្ធសំខាន់ៗ រួមមាន ការតាមដានសេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំអាស៊ានកាលពីកិច្ចប្រជុំកំពូលអាស៊ានលើកទី៣១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ អាទិភាពរបស់សិង្ហបុរី ដែលជាប្រធានអាស៊ាន និងទំនាក់ទំនងខាងក្រៅតំបន់របស់អាស៊ាន។ រដ្ឋមន្ត្រីក៏បានធ្វើការផ្លាស់ប្តូរទស្សនៈស្តីពីបញ្ហាតំបន់ និងអន្តរជាតិ។

ក្នុងការគាំទ្រមូលបទរបស់សិង្ហបុរី "**ភាពរឹងមាំ និងនវានុវត្តន៍**" ឯកឧត្តមទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា កម្ពុជាគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់អាស៊ាន ក្នុងការដោះស្រាយការប្រកួតប្រជែង ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌ សមាហរណកម្មតំបន់ និងការកាត់បន្ថយគម្លាតអភិវឌ្ឍន៍នៅក្នុងអាស៊ាន។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានសង្កត់ធ្ងន់អំពីសារៈសំខាន់ក្នុងការវិនិយោគលើយុវជន ដែលនឹងនាំមកនូវលទ្ធផលដ៏ធំសម្បើម ដែលពួកគេអាចទាញយកឱកាសបានពីការបង្កើតបច្ចេកវិទ្យាថ្មី និងគំនិតបង្កើតថ្មីព្រមទាំងលើកទឹកចិត្តចំពោះសហគ្រិនភាព និងសហគ្រាសធុនតូចនិងមធ្យម ដែលនឹងផ្លាស់ប្តូរអាស៊ានទៅជាតំបន់មួយប្រកបដោយភាពឆ្លាតវៃ និងនវានុវត្តន៍។៚



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

ចំពោះទំនាក់ទំនងខាងក្រៅអាស៊ាន ឯកឧត្តមទេសរដ្ឋមន្ត្រីបានគូសបញ្ជាក់ពីសារៈសំខាន់ក្នុងការស្វែងរកឧត្តមាភិក្រម ដើម្បីដោះស្រាយបញ្ហាការផ្លាស់ប្តូរភូមិសាស្ត្រសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយតំបន់ ដើម្បីធានានូវសន្តិភាព សន្តិសុខ និងវិបុលភាពនៅក្នុងតំបន់ និងក្រៅតំបន់។ ឯកឧត្តមទេសរដ្ឋមន្ត្រីបានសង្កត់ធ្ងន់ពីសារៈសំខាន់នៃវិស័យសេដ្ឋកិច្ច ដែលនឹងបន្តជំរុញជាមួយទំនាក់ទំនងខាងក្រៅរបស់អាស៊ាន ដែលធានានូវការចូលទៅកាន់ទីផ្សារឲ្យកាន់តែប្រសើរសម្រាប់ការនាំចេញ ការធ្វើវិនិយោគកាន់តែច្រើន និងសហប្រតិបត្តិការច្រើនថែមទៀតក្នុងវិស័យពាណិជ្ជកម្ម សេវាកម្ម និងទេសចរណ៍។ ជាសហគមន៍អាស៊ានមួយ ដ៏រឹងមាំ ឯកឧត្តមទេសរដ្ឋមន្ត្រីសង្ឃឹមថា នឹងបានឃើញកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍យ៉ាងច្រើន ដែលផ្តោតលើការកាត់បន្ថយគម្លាតអភិវឌ្ឍន៍ និងសកម្មភាពដទៃទៀត ដែលនាំមកនូវអត្ថប្រយោជន៍ជាក់ស្តែងដល់សហគមន៍ធុរកិច្ចអាស៊ានជាពិសេសសហគ្រាសធុនតូចនិងមធ្យម យុវជន និងសង្គមស៊ីវិល ។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានផ្លាស់ប្តូរទស្សនៈអំពីបញ្ហាតំបន់ និងអន្តរជាតិ ដូចជាបញ្ហាសមុទ្រចិនខាងត្បូង បញ្ហារដ្ឋរ៉ាខាញ់ និងទស្សនទានបឋមស្តីពីនិម្មាបនកម្មតំបន់ឥណ្ឌូ-ប៉ាស៊ីហ្វិក។ ចំពោះបញ្ហាសមុទ្រចិនខាងត្បូង ឯកឧត្តមទេសរដ្ឋមន្ត្រីបានលើកឡើង ដោយការពេញចិត្តចំពោះការវិវឌ្ឍជាវិជ្ជមាន ដែលសម្រេចបានដោយអាស៊ាន និងចិន កាលពីឆ្នាំកន្លងទៅជាពិសេសការអនុម័តក្របខ័ណ្ឌនៃក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង និងការប្រកាសជាផ្លូវការស្តីពីការចាប់ផ្តើមការចរចាអំពីក្រមប្រតិបត្តិនៅសមុទ្រចិនខាងត្បូង។

រដ្ឋមន្ត្រីការបរទេសអាស៊ានបានគាំទ្រកម្មវិធីជំនួយមនុស្សធម៌របស់រដ្ឋាភិបាលមីយ៉ាន់ម៉ារ នៅក្នុងរដ្ឋរ៉ាខាញ់ និងបានស្វាគមន៍ការងាររបស់មជ្ឈមណ្ឌលសម្របសម្រួលជំនួយមនុស្សធម៌អាស៊ាន ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (AHA Centre) ដែលបានធ្វើការជាមួយនឹងយន្តការដែលដឹកនាំដោយរដ្ឋាភិបាលមីយ៉ាន់ម៉ារ ក្នុងការបែងចែកជំនួយមនុស្សធម៌ទៅដល់ជនផ្លាស់ប្តូរទីលំនៅទាំងអស់។៚

ថ្ងៃពុធ ៧រោច ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ភ្នំពេញ ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០១៨